# របាយការណ៍
# ស្តីពី
# លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែសីហា ឆ្នាំ២០១០
# និង ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែកញ្ញា ឆ្នាំ២០១០

(០១/០៨/២០១០-៣១/០៨/២០១០)

អនុវត្តតាមផែនការសកម្មភាពឆ្នាំ២០១០ស្តីពីការត្រួតពិនិត្យគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សម្របសម្រួលជាមួយក្រសួង-ស្ថាប័នជាសមាជិក គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ឱ្យបន្តអនុវត្តការងារទទួលបានលទ្ធផលគួរឱ្យកត់សំគាល់ ។ ជាមួយនេះដែរ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបំផុសលើកទឹកចិត្តឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និង វិស័យឯកជន ដើម្បីអនុវត្តវិធានការមានលក្ខណៈពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនដោយទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

ខែសីហានេះ ក៏ដូចខែកក្កដាកន្លងទៅ មេតំហ្វេតាមីនគ្រាប់(Methamphetamine pill)និងមេតំហ្វេតាមីនទឹកកក(Crystal Methamphetamine) នៅតែជាប្រភេទគ្រឿងញៀន ដែលពួកឈ្មួញគ្រឿងញៀនបានប្រើប្រាស់គ្រប់កលល្បិចដើម្បីនាំចូលមកកម្ពុជា ។ យោងតាមរបាយការណ៍លទ្ធផលនៃកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសក្នុងខែកក្កដាកន្លងទៅ និងខែសីហានេះ នៅទិសខេត្តព្រះវិហារ ពួកឈ្មួញមកពីប្រទេស ឡាវ និង មីយ៉ាន់ម៉ា បានធ្វើសកម្មភាពនាំមេតំហ្វេតាមីនទឹកកក ឆ្លងចូលមកកម្ពុជាតាមច្រកកំពង់ស្រឡៅ២នៃស្រុកឆែប ។ នៅទិសខេត្តស្ទឹងត្រែង ពួកឈ្មួញគ្រឿងញៀនបាននាំគ្រឿងញៀនចូលតាមច្រកជាប់ព្រំដែនជាមួយខេត្តចំប៉ាសាក់(ប្រទេសឡាវ) ដោយមធ្យោបាយធ្វើរជើងក្នុងតំបន់ព្រៃភូមិសាស្ត្រស្មុគស្មាញដែលសមត្ថកិច្ចពិបាកនឹងល្បាតទៅដល់ ។ នៅទិសខេត្តបន្ទាយមានជ័យ ក៏មានការនាំឆ្លងកាត់គ្រឿងញៀនដោយពួកឈ្មួញគ្រឿងញៀនមកពីប្រទេសថៃតាមច្រករបៀងអូរសាយក្បែរភូមិសាស្ត្រ ប៉ុស្តិ៍នគរបាលវរៈការពារព្រំដែនគោកលេខ ៨០៧ ។ នៅទិសខេត្តស្វាយរៀងមានជនជាតិនីហ្សេរីយ៉ាម្នាក់ បានធ្វើការចរាចរមេតំហ្វេតាមីនទឹកកក ពីទីក្រុងបាវិតឆ្លងកាត់ខេត្តព្រៃវែង ត្រូវកងរាជអាវុធហត្ថស្រុកពាមរក៍ខេត្តព្រៃវែងចាប់ខ្លួនបាន ។ ជាមួយគ្នានេះ យើងបានរកឃើញការនាំចូលឱសថដែលមានផ្ទុកសារធាតុ ផ្សឺដូ-អេហ្វេឌ្រីន គ្មានអាជ្ញាប័ណ្ណក្នុងទ្រង់ទ្រាយគួរកត់សំគាល់ ដែលក្រុមឈ្មួញបានបញ្ជាទិញពីប្រទេសកូរ៉េខាងត្បូង ហើយដឹកឆ្លងកាត់ប្រទេសថៃ ចូលមកកម្ពុជាតាមច្រកប៉ោយប៉ែតខេត្តបន្ទាយមានជ័យ ។

នៅរាជធានីភ្នំពេញ មន្ទីរប្រឆាំងគ្រឿងញៀនបានសហការជាមួយនគរបាលរាជធានីភ្នំពេញរកឃើញ និងធ្វើការបង្រ្កាបការផលិតកែច្នៃនូវប្រភេទគ្រឿងញៀនសំយោគATSបានទាន់ពេលវេលា ។ ដោយឡែក អង្គភាពជំនាញនិងខេត្តមួយចំនួនទៀត បានបន្តយកចិត្តទុកដាក់បង្ក្រាបបទល្មើសចរាចរជួញដូរចែកចាយគ្រឿងញៀន នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជាបន្តបន្ទាប់ ក្នុងនោះមាន : មន្ទីរប្រឆាំងគ្រឿងញៀន នគរបាលរាជធានីភ្នំពេញ នគរបាលខេត្តកណ្តាល នគរបាលខេត្តកំពង់ចាម នគរបាលខេត្ត ព្រះសីហនុ នគរបាលខេត្តសៀមរាប នគរបាលខេត្តកំពត នគរបាលខេត្តពោធិសាត់ នគរបាលខេត្តក្រចេះ និងកងរាជអាវុធហត្ថ ស្រុកពាមរក៍ខេត្តព្រៃវែង ។

## II . លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន :

### *ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*

ឯកឧត្តមឧបនាយរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបន្តយកចិត្តទុកដាក់លើកកំពស់វិធានការដែលមានលក្ខណៈពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាអាទិ៍ :

-ការចុះត្រួតពិនិត្យណែនាំការអនុវត្តន៏ផែនការប្រតិបត្តិគំរូត្រួតពិនិត្យគ្រឿងញៀននៅខេត្តបន្ទាយមានជ័យ ។

-ការដឹកនាំគណៈប្រតិភូជាន់ខ្ពស់អន្តរក្រសួងរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ទៅបំពេញទស្សនកិច្ចនៅសាធារណរដ្ឋសង្គមនិយមវៀតណាម( ៩-១៤/៨/២០១០) ។

-ការណែនាំឱ្យរៀបចំឯកសារសៀវភៅសុខភាពសំរាប់អ្នកញៀនគ្រឿងញៀន ការរៀបចំឯកសារសំរាប់អ្នកជម្ងឺចេញ ការរៀបចំសៀវភៅផ្ទាល់ខ្លួនសំរាប់អ្នកញៀនគ្រឿងញៀន និងការរៀបចំកម្មវិធីព្យាបាលប្រចាំថ្ងៃរបស់មណ្ឌលអប់រំ បន្សាបនិងព្យាបាលអ្នកញៀនគ្រឿងញៀន ។

-ការណែនាំឱ្យរៀបចំផែនការគំរូសំរាប់អនុវត្តនៅវិទ្យាល័យឥន្រ្ទទេវី ឱ្យក្លាយទៅជាវិទ្យាល័យពណ៌បៃតងគំរូ ។

-ការណែនាំឱ្យស្រង់ស្ថិតិបទល្មើសគ្រឿងញៀនរយៈពេល ៨ ខែ ឆ្នាំ២០១០ និងស្ថិតិរឹបអូសប្រេងម្រះព្រៅភ្នំ ។

-ការណែនាំក្នុងការរៀបចំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

ក្នុងនាមឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឯកឧត្តម **កៅ ខុនជាក៏** អនុប្រធានអាជ្ញាធរជាតិ បានអញ្ជើញចូលរួមជាអធិបតីនៅក្នុងទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦/៦/២០១០ នៅខេត្តព្រៃវែង កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១០ ( ដោយសារខេត្តព្រៃវែងមានកម្មវិធីមមាញឹកកាលពីខែមិថុនា ទើបរៀបចំទិវានេះនៅក្នុងខែសីហាជំនួសវិញ) ។

### *១_ការកាត់បន្ថយតម្រូវការគ្រឿងញៀន :*

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់ជំរុញដល់ក្រសួង-ស្ថាប័នជាសមាជិក និងបំផុសលើកទឹកចិត្តឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និង វិស័យឯកជន ដើម្បីធ្វើការផ្សព្វផ្សាយអប់រំសំដៅលើកកំពស់ការយល់ដឹងជាសាធារណៈពីគ្រោះថ្នាក់នៃគ្រឿងញៀន ជាអាទិ៍ :

-ការចូលរួមជាវាគ្មិនក្នុងអង្គសិក្ខាសាលាស្តីពី "ដើម្បីសុខភាព ត្រូវបដិសេធគ្រឿងញៀន" ដែលរៀបចំដោយសកល

វិទ្យាល័យបាត់ដំបង(៣០/៧/២០១០) ។

-ការបណ្តុះបណ្តាលដល់ក្រុមជនបង្គោលតាមគោលដៅសំខាន់ៗចំនួន ៤៥០ នាក់ (លោកគ្រូ-អ្នកគ្រូតាមសាលាគោលដៅ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងឃុំគោលដៅ ម្ចាស់ផ្ទះសំណាក់ សណ្ឋាគារ ក្លឹបកំសាន្ត) នៅខេត្តបន្ទាយមានជ័យ និង ខេត្តបាត់ដំបង ដើម្បីអ្នកទាំងនោះមានចំណេះដឹងជាមូលដ្ឋានអំពីគ្រឿងញៀន ហើយនាំយកចំណេះដឹងនេះទៅផ្សព្វផ្សាយអប់រំបន្តដល់មុខសញ្ញាងាយទទួលរងគ្រោះផ្សេងទៀតនៅតាមមូលដ្ឋានសហគមន៍ ។

-ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ បានជូនដំណឹងដល់ក្រុមហ៊ុននាំចេញ-នាំចូលផលិតកម្មភាពយន្តនិងវីដេអូបានចំនួន ១២០ក្រុមហ៊ុនបន្ថែមទៀតឱ្យបញ្ចូលសារអប់រំពីគ្រឿងញៀនទៅក្នុងផលិតផលនៃផលិតកម្មរបស់ខ្លួន ។

-ក្រសួងអប់រំយុវជននិងកីឡា បានបង្កើតគណៈកម្មាធិការអន្តរនាយកដ្ឋាន ប្រយុទ្ធនឹងជម្ងឺអេដស៍ និងគ្រឿងញៀន ដើម្បីចូលរួមអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និង គោលការណ៍ណែនាំផ្សេងៗ ស្តីពីការប្រយុទ្ធនឹងជម្ងឺអេដស៍ និងគ្រឿងញៀនក្នុងវិស័យអប់រំ ។

-អង្គការមូស្លីមអេដស៍កម្ពុជា បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្គោល កាលពីថ្ងៃទី១២-១៣/០៨/ ២០១០ នៅសណ្ឋាគារហូលីដេភ្នំពេញ ដើម្បីអនុវត្តសាកល្បងគំរោងស្តីពី "ការលើកកំពស់បរិស្ថានសាលារៀនឱ្យកាន់តែល្អប្រសើរឡើងតាមរយៈផ្តល់ការអប់រំគ្មានការប្រើប្រាស់គ្រឿងញៀននៅក្នុងសាលារៀន និងការផ្តល់សេវាគាំទ្រផ្អែកលើមូលដ្ឋានសហគមន៍នៅកម្ពុជា" ។

-បណ្តាខេត្តនិងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនក៏បានបន្តការយកចិត្តទុកដាក់ចូលរួមក្នុងការផ្សព្វផ្សាយអប់រំ ប្រចាំខែពីគ្រោះថ្នាក់នៃគ្រឿងញៀននេះ សរុបបានចំនួន **៩.៨៨៩ នាក់** ។

### ***២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន :***

ខែសីហាឆ្នាំ២០១០ បង្ក្រាបបទល្មើសបាន**៣៧ករណី**[១] ឃាត់ខ្លួនជនល្មើស**៦០**នាក់(ប្រុស៤៥នាក់,ស្រី១៥នាក់) ក្នុងនោះ ជនជាតិខ្មែរ៤៨នាក់(ប្រុស៣៦នាក់-ស្រី១២នាក់), វៀតណាម៧នាក់(ប្រុស៤-ស្រី៣), ថៃ១នាក់(ប្រុស), ឡាវ ២នាក់(ប្រុស), ចិនដីគោក១នាក់(ប្រុស), នីហ្សេរីយ៉ា១នាក់(ប្រុស) ។

**វត្ថុតាងចាប់យក** មេតំហ្វេតាមីន **WY ១០.១២៨** គ្រាប់, ម្សៅមេតំហ្វេតាមីន **ICE ១.២៩៧,១៦** ក្រាម (ក្នុងនោះមាន ១០០ ក្រាម ជាករណីរបស់កងរាជអាវុធហត្ថស្រុកពាមរក៍ ខេត្តព្រៃវែង), អ៊ិចស្តាស៊ី៤៧៥គ្រាប់, ហេរ៉ូអ៊ីន២៧ ក្រាម, ម្សៅពណ៌ស៤៨២,៦៣ក្រាម, កញ្ឆាកិនរួច២៣២ក្រាម, ឱសថមានផ្ទុកសារធាតុ ផ្សឺដូ-អេហ្វេឌ្រីន មានផ្លាកសញ្ញាអក្សរ col col co ចំនួន៤៨កេស្ត=២៦៨កំប៉ុង=**១២.៨៦៤.០០០គ្រាប់** និងទំនិញចំនួន១០មុខទៀត, ប្រាក់ដុល្លារក្លែងក្លាយក្រដាស១០០ចំនួន៥០សន្លឹក, ដង្កាំ១, ពុម្ពសង្កត់៤, ជញ្ជីងថ្លឹង៥, រថយន្ត៤គ្រឿង, ម៉ូតូ៦គ្រឿង, ឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន ។ ដោយឡែក លើការប្រមូលទិន្នន័យសារធាតុគីមីផ្សំអគ្គលេខាធិការដ្ឋាន បានសហការជាមួយក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) ធ្វើការប្រមូលនិងបូកសរុបទិន្នន័យ

---

(១) របាយការណ៍របស់មន្ទីរប្រឆាំងគ្រឿងញៀនមានតែ៣៥ករណីប៉ុណ្ណោះ តែរបាយការណ៍របស់អាជ្ញាធរជាតិបានបូកបន្ថែមករណីបង្ក្រាបដោយកងរាជអាវុធហត្ថស្រុកពាមរក៍ ខេត្តព្រៃវែង ១ករណី និង ករណីនាំឱសថដែលមានផ្ទុកសារធាតុ ផ្សឺដូ-អេហ្វេឌ្រីន ១ករណី សរុបមានចំនួន ៣៧ ករណី ។

សារធាតុគីមីផ្សំដែលមានអាជ្ញាប័ណ្ណនាំចូលប្រចាំខែសីហាឆ្នាំ២០១០សរុបមានចំនួន **5.933.440** Kg (បញ្ជីសារធាតុគីមីផ្សំលំអិតមាននៅក្នុងតារាងឧបសម្ព័ន្ធ) ។

ដើម្បីលើកកំពស់ប្រសិទ្ធភាពការងារគ្រប់គ្រងនិងត្រួតពិនិត្យសារធាតុគីមីផ្សំ ក្នុងខែសីហានេះ នាយកដ្ឋានស្រាវជ្រាវនិងត្រួតពិនិត្យនៃអគ្គលេខាធិការដ្ឋាន អជបគញ បានសហការជាមួយមន្ត្រីជំនាញរបស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្នុងការរៀបចំផែនការ ឆ្នាំ២០១១ ស្តីពីការពង្រឹងការងារគ្រប់គ្រងនិងត្រួតពិនិត្យសារធាតុគីមីផ្សំ ។

## ***៣-ការព្យាបាលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងការកាត់បន្ថយគ្រោះថ្នាក់នានា :***

យើងបានជួបពិភាក្សាជាមួយក្រុមការងារបច្ចេកទេសវៀតណាម(២៦/៧/២០១០) ដែលអញ្ជើញមកកម្ពុជា ក្នុងគោលបំណងជំរុញការសាងសង់មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនឱ្យបានលឿន ។ ភាគីវៀតណាមបាន ឯកភាពឱ្យកម្ពុជាលើកសំណើជាផ្លូវការចំពោះការស្នើសុំក្រុមជំនាញការមកជួយធ្វើការសិក្សានិងគូរប្លង់មជ្ឈមណ្ឌល ។

ថ្ងៃទី០៩ដល់ថ្ងៃទី១៤ខែសីហាឆ្នាំ២០១០ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ទៅបំពេញទស្សនកិច្ចនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ។ ក្នុងអំឡុងពេលទស្សនកិច្ច ប្រតិភូកម្ពុជាបានស្នើសុំឱ្យភាគីវៀតណាមពិនិត្យលទ្ធភាពជួយដល់កម្ពុជាក្នុងការកសាងមជ្ឈមណ្ឌលជាតិព្យាបាលអ្នកញៀនឱ្យបានឆាប់រហ័ស និងជួយបណ្តុះបណ្តាលមន្ត្រីផ្នែកគ្រប់គ្រងមណ្ឌល, មន្ត្រីផ្នែករៀបចំផែនការ, គ្រូពេទ្យជំនាញផ្នែកព្យាបាលអ្នកញៀនសំរាប់ថ្នាក់ជាតិ សំរាប់មណ្ឌលបណ្តោះអាសន្ន និងមន្ទីរពេទ្យបង្អែករាជធានី-ខេត្តជំហានដំបូងចំនួន ៤៧រូប និងជំហានបន្ទាប់ចំនួន៣០រូប និងបានស្នើសុំឱ្យភាគីវៀតណាម ជួយផ្តល់នូវសម្ភារៈ បរិក្ខារពេទ្យ ឱសថសំរាប់បន្សាបព្យាបាលគ្រឿងញៀននិងឱសថផ្សេងៗទៀត សំរាប់ព្យាបាលអាការៈដែលជាផលប៉ះពាល់មកពីគ្រឿងញៀន ។ ចំពោះទីក្រុងហូជីមិញកម្ពុជាបានស្នើសុំឱ្យបន្តជួយដល់មណ្ឌលបណ្តោះអាសន្ន ឱកាសខ្ញុំ របស់សាលារាជធានី និងស្នើសុំឱ្យជួយរកដៃគូដើម្បីពង្រឹងមណ្ឌលបណ្តោះអាសន្ន ពិភពនៃក្តីសង្ឃឹម របស់សាលាខេត្តបាត់ដំបង ។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានផ្តល់របបឧបត្ថម្ភដល់គ្រប់មណ្ឌលបណ្តោះអាសន្នសំរាប់អប់រំបន្សាបនិងព្យាបាលអ្នកញៀនគ្រឿងញៀន តាមគោលការណ៍របស់រាជរដ្ឋាភិបាល ហើយបានផ្តល់ដល់មណ្ឌល ឱកាសខ្ញុំ របស់សាលារាជធានីភ្នំពេញ នូវផ្តល់ម៉ាស៊ីនថតចម្លង ១គ្រឿង ។

ថ្ងៃទី២៥ខែសីហាឆ្នាំ២០១០ យើងបានចូលរួមពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិនៅទីស្តីការគណៈរដ្ឋមន្ត្រីដោយបានស្នើសុំក្រុមប្រឹក្សាអ្នកច្បាប់នៃគណៈរដ្ឋមន្ត្រីលុបមាត្រា៤នៃសេចក្តីព្រាងអនុក្រឹត្យនេះ ។

បានអនុញ្ញាតឱ្យមន្ត្រីសម្របសម្រួលគំរោង H83 រួមជាមួយអង្គការ UNODC ចុះទៅខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និង ខេត្តសៀមរាប ដើម្បីប្រមូលរបាយការណ៍ស្តីពីសកម្មភាពរបស់ក្រុមពិគ្រោះយោបល់ និងឈានទៅធ្វើការបូកសរុបបញ្ចប់គំរោង ព្រមទាំងបានចាត់មន្ត្រីទៅចូលរួមក្នុងពិធីសម្ពោធទីស្នាក់ការនិងអគារថ្មីរបស់សមាគមអប់រំព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀននិងបណ្តុះបណ្តាលចំណេះដឹង នៅថ្ងៃទី០៩ខែសីហាឆ្នាំ២០១០ ។

**ចំពោះការកាត់បន្ថយគ្រោះថ្នាក់** យើងបានចូលរួមនៅក្នុងកិច្ចប្រជុំពិភាក្សាការងារជាមួយសមាជិកក្រុមការងារ

គ្រឿងញៀន-អេដស៍(០៣/៨/២០១០) និងបានចាត់មន្ត្រីជំនាញទៅចូលរួមក្នុងកិច្ចប្រជុំក្រុមការងាររួមរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលរៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ដើម្បីពង្រឹងការងារទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍/ជម្ងឺអេដស៍ ជាលក្ខណៈពហុវិស័យ និងបង្កើននូវយន្តការឆ្លើយតបប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមរយៈការគ្រប់គ្រងនិងធ្វើចលនាប្រភពធនធានពីគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ ។

អង្គការKHANA AusAID USAID FHI បានបន្ថែមថវិកាមួយចំនួនសំរាប់គាំទ្រកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រឿងញៀន ដោយបានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់របស់ខេត្តមួយចំនួន ។

## ៤. ការពង្រឹងសមត្ថភាពអនុវត្តច្បាប់

នៅក្នុងឱកាសបំពេញទស្សនកិច្ចនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានស្នើសុំភាគីវៀតណាមជួយបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់គ្រឿងញៀន សម្រាប់ថ្នាក់ខេត្តជាប់ព្រំដែនជាមួយវៀតណាមចំនួន១២រូប, សម្រាប់ថ្នាក់ក្រុង-ស្រុកជាប់ព្រំដែនជាមួយវៀតណាមចំនួន២៨ក្រុង-ស្រុក, សម្រាប់មន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ-សង្កាត់ជាប់ព្រំដែនជាមួយវៀតណាមចំនួន៧៩ឃុំ/សង្កាត់ និងមន្ត្រីមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន សរុបទាំងអស់ចំនួន១៤៩រូប ។ ភាគីទាំងពីរនឹងបន្តជំរុញការរៀបចំបង្កើតការិយាល័យទំនាក់ទំនងព្រំដែនថ្មីចំនួន២កន្លែង នៅច្រកត្រពាំងផ្លុងខេត្តកំពង់ចាម និង ច្រកភ្នំដិនខេត្តតាកែវ ដើម្បីស្នើសុំទៅUNODC ព្រមទាំងបានឯកភាពគ្នាជំរុញការរៀបចំភូមិ ឃុំ សាលារៀន នៅតាមព្រំដែនគ្មានគ្រឿងញៀន ។

អគ្គលេខាធិការ អជបគញ បានជួបពិភាក្សាការងារជាមួយអនុប្រធានសេនាទុត្យ័ន្ទ នៃអគ្គកុងស៊ុលសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងហុងកុង(២៨/៧/២០១០) ដែលមានបំណងចង់មកបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសក្នុងការស៊ើបអង្កេតហិរញ្ញវត្ថុដល់មន្ត្រីអនុវត្តច្បាប់កម្ពុជា ។ យើងបានគាំទ្រចំពោះគោលបំណងនេះ ដោយសារវាមានការទាក់ទងច្រើនជាមួយឧក្រិដ្ឋកម្មឆ្លងដែននានា ដូចជា អំពើភេរវកម្ម ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស ការលាងលុយកខ្វក់ ហើយភាគីភ្ញៀវនឹងជូនព័ត៌មានជាថ្មីនៅក្នុងខែកញ្ញាឆ្នាំ២០១០ ។

អគ្គលេខាធិការដ្ឋាន អជបគញ ក្រោមគំរោងទ្វេភាគី កម្ពុជា-កូរ៉េ ស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា បានបើកវគ្គបណ្តុះបណ្តាលសមត្ថភាពមន្ត្រីអនុវត្តច្បាប់ (នគរបាលខេត្ត-ស្រុក-ខណ្ឌ-ឃុំ-សង្កាត់, កងរាជអាវុធហត្ថខេត្ត-ស្រុកខណ្ឌ, កម្លាំងវរៈព្រំដែន, គយ-រដ្ឋាករ, កាំកុងត្រូល) នៅខេត្តបន្ទាយមានជ័យ បានចំនួន២២០នាក់, នៅខេត្តបាត់ដំបង បានចំនួន២២០នាក់ ខេត្តប៉ៃលិន បានចំនួន២២០នាក់ ។ ជាមួយនេះដែរ អង្គការ AUSAID បានផ្តល់ការបណ្តុះបណ្តាលនៅខេត្តកោះកុង បានចំនួន១២០នាក់ ខេត្តព្រះសីហនុ បានចំនួន១២០នាក់ (សរុប**៩០០**នាក់) ។

ដោយឡែក មន្ទីរប្រឆាំងគ្រឿងញៀន តាមសំណើរបស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានធ្វើការបណ្តុះបណ្តាលមន្ត្រីនគរបាលអំពីនីតិវិធីក្នុងការត្រួតពិនិត្យគ្រឿងញៀន និងនីតិវិធីក្នុងការធ្វើបច្ចុប្បន្នភាពទិន្នន័យព័ត៌មានគ្រឿងញៀនតាមគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន សរុបបានចំនួន ២៤៥ នាក់ ។

-ខេត្តកណ្តាលបានបើកកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែន(BLO) ជាមួយការិយាល័យBLO នៃខេត្តអានយ៉ាន(វៀតណាម) ក្នុងការផ្លាស់ប្តូរសភាពការណ៍ បទពិសោធន៍ ព័ត៌មានគ្រឿងញៀនពីគ្នាទៅវិញទៅមក ។ ចំពោះព័ត៌មាន

សម្ងាត់ ការស្រាវជ្រាវស៊ើបអង្កេតរកមុខសញ្ញ គួរបង្កើតជាក្រុមការងារឬធ្វើរបាយការណ៍ដោយឡែក ដោយមានភ្ជាប់ជាមួយនូវសាវតាជាតិ រូបថត ប្រវត្តិសកម្មភាព ផ្ញើឱ្យគ្នាទៅវិញទៅមកតាមក្រោយ ។ កិច្ចប្រជុំនេះត្រូវបានធ្វើកំណត់ហេតុជាភាសាជាតិនៃប្រទេសទាំងពីរ និងធ្វើពិធីចុះហត្ថលេខាដោយប្រធានប្រតិភូទាំងសង្ខាង និងបានឯកភាពគ្នារៀបចំកិច្ចប្រជុំលើកក្រោយនៅ ខេត្តអានយ៉ានតាមការផ្លាស់ប្តូរវេនគ្នា ។

ជាមួយបណ្តាប្រទេសក្នុងតំបន់ យើងបានចាត់មន្ត្រីជំនាញចំនួន២រូប ទៅចូលរួមសិក្ខាសាលាស្តីពីកម្មវិធី Global Smart ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក នៅទីក្រុងបាងកក ប្រទេសថៃ ។ គោលបំណងរបស់សិក្ខាសាលា សំខាន់គឺការធ្វើឱ្យមានភាពកាន់តែប្រសើរឡើងនូវកម្មវិធីGlobal Smart( ការចែករំលែកព័ត៌មានគ្រឿងញៀនATS) និងការឆ្លើយតបក៏រិតជាតិ ព្រមទាំងបានពិភាក្សាលើជំហានបន្ទាប់សំរាប់អនុវត្តកម្មវិធីនេះ នៅក្នុងក៏រិតតំបន់នាពេលអនាគត ។

***៥-កិច្ចសហប្រតិបត្តិការអន្តរជាតិ :***

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានដឹកនាំគណៈប្រតិភូអន្តរក្រសួងជាន់ខ្ពស់មួយក្រុម ទៅបំពេញទស្សនកិច្ច នៅសាធារណរដ្ឋសង្គមនិយមវៀតណាម តាមការអញ្ជើញរបស់ឯកឧត្តម **ទ្រឿង វិញចុង** ឧបនាយករដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន អេដស៏ និងពេស្យាចារនៃសាធារណរដ្ឋសង្គមនិយមវៀតណាម (ចំពោះលទ្ធផលនៃដំណើរទស្សនកិច្ចនេះដូចមានសេចក្តី រាយការណ៍នៅក្នុងការងារព្យាបាល និងការងារពង្រឹងសមត្ថភាពអនុវត្តច្បាប់) ។

## III . ការសន្និដ្ឋាន និង វាយតម្លៃ :

ខែសីហានេះ យើងបានបន្តយកចិត្តទុកដាក់លើការងារលើកកំពស់ការយល់ដឹងជាសាធារណៈពីគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈការផ្សព្វផ្សាយអប់រំផង ការបណ្តុះបណ្តាលក្រុមជនតាមគោលដៅសំខាន់ៗផង ព្រមទាំងអនុវត្តនូវកម្មវិធីកាត់បន្ថយគ្រោះថ្នាក់នានាដែលបណ្តាលពីគ្រឿងញៀន ទទួលបានលទ្ធផលគួរកត់សំគាល់ ។ នេះគឺជាការអនុវត្តន៏នូវចំណុចខ្វះខាតដែលយើងធ្លាប់បានធ្វើការសន្និដ្ឋាននិងវាយតម្លៃពីបណ្តាខែមុនៗ ។ ប៉ុន្តែបញ្ហាប្រឈមរបស់យើងគឺការរៀបចំឯកសារផ្សព្វផ្សាយទាំងឡាយដែលមានខ្លឹមសារពហុវិស័យពាក់ព័ន្ធនឹងក្រសួង-ស្ថាប័នដទៃទៀត នៅមានភាពយឺតយ៉ាវដែលទាមទារត្រូវតែជំរុញការងារនេះឱ្យបានសកម្មថែមទៀត ដើម្បីឈានទៅសំរេចជាស្ថាពរនៅក្នុងខែកញ្ញាខាងមុខនេះ ។

ចំពោះការងារអនុវត្តច្បាប់ យើងបង្ក្រាបបទល្មើសបានច្រើនករណីបើប្រៀបធៀបខែកក្កដាកន្លងទៅ ទាំងករណីជួញដូរចែកចាយនិងករណីផលិតកែច្នៃនូវប្រភេទគ្រឿងញៀនគ្រប់ប្រភេទ ។ ប៉ុន្តែកត់សំគាល់ឃើញ ការបង្ក្រាបបទល្មើសទាំងនោះ ភាគច្រើនធ្វើឡើងដោយអង្គភាពជំនាញថ្នាក់ជាតិ ឯខេត្តដទៃទៀតបង្ក្រាបបទល្មើសបានតិច ហើយភាគច្រើនជាបទល្មើសជាក់ស្តែង ។ ចំណុចនេះ ទាមទារឱ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត, ប្រធានស្ថាប័នអនុវត្តច្បាប់របស់រាជធានី-ខេត្ត ត្រូវយកចិត្តទុកដាក់បំប៉នជំនាញនិងការទទួលខុសត្រូវចំពោះមន្ត្រីក្រោមឱវាទ ជាពិសេសអាជ្ញាធរមានសមត្ថកិច្ចនៅឯមូលដ្ឋាន ដើម្បីធានាក្នុងការអនុវត្តន៏នូវវិធានការជំនាញ( ការប្រើប្រាស់កម្លាំងបង្កប់) គួបផ្សំនឹងការអនុវត្តន៏វិធានការរដ្ឋបាលឱ្យបានហ្មឹងម៉ាត់និងជាប់ជាប្រចាំ ជាអាទិ៏ ការធ្វើកិច្ចសន្យារដ្ឋបាលជាមួយម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្តនានា ។

ចំពោះការងារព្យាបាល ទោះបីយើងមានការយឺតយ៉ាវលើការងារសាងសង់មជ្ឈមណ្ឌលព្យាបាលថ្នាក់ជាតិ ប៉ុន្តែ

ក្រសួងសុខាភិបាល បានរៀបចំគោលការណ៍ណែនាំស្តីពីការបន្សាបគ្រឿងញៀនសំរាប់មណ្ឌលបណ្តោះអាសន្ន និងបានជំរុញយន្តការអនុវត្តគោលការណ៍នេះ សំដៅពង្រឹងបច្ចេកទេសវេជ្ជសាស្ត្រសំរាប់ការបន្សាបគ្រឿងញៀន ។ ប៉ុន្តែការចាត់តាំងអនុវត្តនូវគោលការណ៍ណែនាំទាំងនេះ ហាក់ដូចជាមិនទាន់សកម្មនៅឡើយនៅតាមរាជធានី-ខេត្តមួយចំនួន ។

## IV. ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែកញ្ញា ឆ្នាំ២០១០ :

ដូចបានធ្វើការសន្និដ្ឋាននិងវាយតម្លៃអំពីសភាពការណ៍គ្រឿងញៀន និងចំណុចប្រឈមក្នុងការអនុវត្តន៏យុទ្ធសាស្ត្រ ក៏ដូចជាការដោះស្រាយបញ្ហាខាងលើ អាជ្ញាធរជាតិបានដាក់ចេញនូវទិសដៅដើម្បីអនុវត្តបន្តដូចតទៅ :

### ***១.ការងារកាត់បន្ថយតម្រូវការគ្រឿងញៀន :***

-ត្រៀមចូលរួមជាវាគ្មិននៅក្នុងវគ្គបណ្តុះបណ្តាលអ្នកនិពន្ធជំនាន់ទី២៦ ក្រោមប្រធានបទ ស្តីពីស្ថានភាពគ្រឿងញៀននៅកម្ពុជា (០២/៩/២០១០) ។

-បន្តការរៀបចំបង្កើតផ្ទាំងរូបភាព ខិត្តបណ្ណ័ ដែលមានខ្លឹមសារប្រើប្រាស់ផ្សព្វផ្សាយជាលក្ខណៈអន្តរក្រសួង-ស្ថាប័នពាក់ព័ន្ធ សំរាប់ធ្វើការផ្សព្វផ្សាយនៅតាមសណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត នានា ។

-បន្តកិច្ចសម្របសម្រួលជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ឱ្យជួយអន្តរាគមន៍ទៅក្រុមហ៊ុនទូរស័ព្ទចល័ត ក្នុងការបញ្ចូលសារអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀនទៅកាន់អតិថិជនរបស់ខ្លួន ។

-បន្តកិច្ចសហការជាមួយក្រសួងជាសមាជិក ក្នុងការជំរុញការផ្សព្វផ្សាយអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ (វិទ្យុ-ទូរទស្សន៍ រដ្ឋ-ឯកជន) ជាពិសេស តាមកម្មវិធីប្រចាំខែដែលផ្តល់ដោយស្ថានីយ៍ទូរទស្សន៍ CTN ។

-បំផុសលើកទឹកចិត្តឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងវិស័យឯកជន ក្នុងការចូលរួមផ្សព្វផ្សាយ លើកកំពស់ការយល់ដឹងពីគ្រឿងញៀន ។

-បន្តកិច្ចសហការជាមួយអង្គការ KHANA AusAID USAID FHI ដើម្បីបញ្ជ្រាបកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ទៅក្នុងវគ្គបណ្តុះបណ្តាលសមត្ថភាពមន្ត្រីអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀននៅខេត្តកំពង់ស្ពឺ សៀមរាប ព្រះវិហារ ។

### ***២.ការព្យាបាល ស្តារនីតិសម្បទា និង សមាហរណកម្ម និងការកាត់បន្ថយគ្រោះថ្នាក់នានា :***

-ជំរុញការងារសាងសង់មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅខេត្តព្រះសីហនុ ។

-ត្រៀមរៀបចំការប្រជុំមួយជាមួយក្រុមការងារអន្តរក្រសួងពាក់ព័ន្ធនឹងដំណើរការសាងសង់មជ្ឈមណ្ឌល ដើម្បីពិភាក្សាលើយោបល់ ដែលបានផ្តល់ដោយក្រុមបច្ចេកទេសវៀតណាម ។

-បន្តការរៀបចំសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងការរៀបចំសេចក្តីព្រាងស្តីពីតំរូវការអប្បបរមាក្នុងការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

-បន្តការតាមដានសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលបានដាក់ជូនក្រុមប្រឹក្សាអ្នកច្បាប់របស់ទីស្តីការគណៈរដ្ឋមន្ត្រីពិនិត្យ ។

-រៀបចំដកពិសោធន៏ឯកសារសៀវភៅសុខភាពសំរាប់អ្នកញៀនគ្រឿងញៀន និងកម្មវិធីព្យាបាលប្រចាំថ្ងៃរបស់មណ្ឌល អប់រំ បន្សាប និងព្យាបាលអ្នកញៀនគ្រឿងញៀន ដែលការងារនេះនឹងចាប់ផ្តើមអនុវត្តនៅខេត្តបន្ទាយ-

មានជ័យ និង ខេត្តបាត់ដំបង ។

-បន្តការរៀបចំផែនការគំរូសំរាប់អនុវត្តនៅវិទ្យាល័យឥន្ទ្រទេវី ឱ្យក្លាយជាវិទ្យាល័យពណ៌បៃតងគំរូ ។

## ៣.ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

-បន្តការស្រាវជ្រាវអត្តសញ្ញាណជនសង្ស័យពាក់ពន្ធ័ករណីនាំចូលឱសថដែលមានផ្ទុក សារធាតុផ្សឺដូ-អេហ្វេឌ្រីន តាមច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

-បន្តការស្រាវជ្រាវរកប្រភពសារធាតុគីមីផ្សំគ្រឿងញៀន និងអត្តសញ្ញាណក្រុមផលិតកែច្នៃគ្រឿងញៀន ។

-បន្តការប្រមូលទិន្នន័យសារធាតុគីមីផ្សំ និង ឱសថដែលមានសារធាតុញៀន ដែលនាំចូលស្របច្បាប់ ។

-រៀបចំពង្រឹងយន្តការក្នុងការប្រមូលព័ត៌មាន និងទប់ស្កាត់ការលួចនាំចូលសារធាតុគីមីផ្សំពីប្រទេសជិតខាង ។

-សម្របសម្រួលជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ដើម្បីជំរុញឱ្យអាជ្ញាធរមូលដ្ឋាន យកចិត្តទុកដាក់ធ្វើកិច្ចសន្យារដ្ឋបាលឱ្យបានហ្មឹងម៉ាត់ ជាមួយម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត និង កន្លែងសប្បាយនានា នៅមូលដ្ឋានរបស់ខ្លួន ។

-បន្តការណែនាំដល់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឱ្យមានប្រសិទ្ធភាព ។

## ៤.ពង្រឹងសមត្ថភាពអនុវត្តច្បាប់

-បន្តធ្វើការសម្របសម្រួលជាមួយអនុប្រធានសេនានុព័ន្ធ ស្ថានអគ្គកុងស៊ុលសហរដ្ឋអាមេរិក ប្រចាំនៅទីក្រុងហុងកុងដើម្បីជំរុញការបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសក្នុងការស៊ើបអង្កេតហិរញ្ញវត្ថុដល់មន្ត្រីអនុវត្តច្បាប់កម្ពុជា ។

-បន្តកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-កូរ៉េ រៀបចំវគ្គបណ្តុះបណ្តាលសមត្ថភាពមន្ត្រីអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀននៅខេត្តមួយចំនួនទៀតក្នុងចំណោមរាជធានី-ខេត្តទាំង១០ ដែលមានក្នុងគំរោងរបស់អគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ ។

-សហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស ដើម្បីធ្វើសម្រង់ស្ថិតិបទល្មើសគ្រឿងញៀនរយៈពេល ៨ ខែ ឆ្នាំ២០១០ ។

-សហការជាមួយក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ និងក្រសួងបរិស្ថាន ដើម្បីធ្វើសម្រង់ស្ថិតិការរឹបអូសប្រេងម្រេះព្រៅភ្នំ រយៈពេល ៨ខែ ឆ្នាំ២០១០ ។

-បន្តការរៀបចំវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ឱ្យមានការយល់ដឹងពីបញ្ហាគ្រឿងញៀន និងការរីករាលដាលមេរោគអេដស៍ ជម្ងឺអេដស៍បណ្តាលមកពីការប្រើបំពានគ្រឿងញៀន នៅតាមបណ្តាខេត្តចំនួន ៤ ទៀត គឺ ខេត្តសៀមរាប ថ្ងៃ៨-១០/៩/២០១០(សិក្ខាកាម១៧៩នាក់), ខេត្តព្រះវិហារ ថ្ងៃទី១៣-១៥/៩/២០១០(សិក្ខាកាម១២០នាក់, ខេត្តស្ទឹងត្រែង ថ្ងៃទី២៧-២៨/៩/២០១០(សិក្ខាកាម១០០នាក់ និង ខេត្តកំពង់ស្ពឺ ថ្ងៃទី៣០/៩-០១/១០/២០១០(សិក្ខាកាម១០០នាក់) ។

## ៥.កិច្ចសហប្រតិបត្តិការអន្តរជាតិ

-សហការជាមួយអង្គការ UNODC អនុតំបន់ ដើម្បីរៀបចំសិក្ខាសាលាគំរោង I 61 នៅខេត្តសៀមរាប( ៣០ សីហា

ដល់ ០៣ កញ្ញា ឆ្នាំ២០១០) សំដៅពង្រឹងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន នៃបណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គ ។

-បញ្ជូនមន្ត្រីអនុវត្តច្បាប់ចំនួន២០រូបទៅទទួលការបណ្តុះបណ្តាលស្តីពីបច្ចេកទេសស៊ើបអង្កេតបទឧក្រឹដ្ឋ ដែលពាក់ព័ន្ធទៅនឹងគ្រឿងញៀន និងវិភាគការវាយតម្លៃលើសញ្ញាណនៃគ្រឿងញៀន នៅសាធារណរដ្ឋសង្គមនិយមវៀតណាម (ថ្ងៃទី១៩-២៤/៩/២០១០) ។

-ត្រៀមលក្ខណៈបញ្ជូនមន្ត្រីអនុវត្តច្បាប់ចំនួន៣០រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលការអនុវត្តន៏ច្បាប់គ្រឿងញៀន នៅសាលានគរបាលទីក្រុងគុនមិញ ខេត្តយូណាន សាធារណរដ្ឋប្រជាមានិតចិនថ្ងៃ១១-២៦ខែតុលាឆ្នាំ២០១០ ។

ទន្ទឹមនេះ ដើម្បីអនុវត្តបានសំរេចផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀនខាងលើ អាជ្ញាធរជាតិនឹងបន្តជំរុញការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន, ការកែសម្រួលច្បាប់ថ្មី ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ការត្រៀមលក្ខណៈត្រួតពិនិត្យការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ, ការបន្តជំរុញការកសាងផែនការសកម្មភាពជាតិ៥ឆ្នាំ(២០១១-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ការបន្តជំរុញការធ្វើបច្ចុប្បន្នភាពទិន្នន័យព័ត៌មានគ្រឿងញៀន តាមគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន, ការបន្តអនុវត្តន៏ផែនការប្រតិបត្តិគំរូត្រួតពិនិត្យគ្រឿងញៀននៅខេត្តបន្ទាយមានជ័យ, ការរៀបចំផែនការគំរូសំរាប់អនុវត្តនៅវិទ្យាល័យឥន្ទ្រទេវីឱ្យក្លាយទៅជាវិទ្យាល័យពណិបែតងគំរូគ្មានគ្រឿងញៀន។

**អគ្គលេខាធិការ**

**<u>ចំលងជូន</u>** :

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

-ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អជបគញ

(ដើម្បីជូនជ្រាប)

-ក្រសួងសមាជិក អ.ជ.ប.គ.ញ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត

-នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

(ដើម្បីមុខការ)

-ឯកសារ-កាលប្បវត្តិ

## អង្គភាពប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ខែសីហា ឆ្នាំ២០១០

| ល.រ | អង្គភាពបង្ក្រាប | សរុបរួម | | | ផលិត ចរាចរ ជួញដូរចែកចាយ | | | ប្រើប្រាស់គ្រឿងញៀន | | | ចាប់តាមដីកា | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី |
| ១ | មន្ទីរប្រឆាំងគ្រឿងញៀន | **៧** | **១៥** | **៤** | ៧ | ១៥ | ៤ | | | | 0 | ១ | 0 |
| ២ | មន្ទីរ គ្រ.ញ សហការជាមួយ ន.ប ខេត្តបន្ទាយមានជ័យ | **១** | **១** | **០** | ១ | ១ | 0 | | | | | | |
| ៣ | មន្ទីរ គ្រ.ញ សហការជាមួយ ន.ប ខេត្តព្រះវិហារ | **១** | **១** | **០** | ១ | ១ | 0 | | | | | | |
| ៤ | ន.ប ភ្នំពេញ | **១៣** | **២៣** | **៦** | ១១ | ១៦ | ៥ | ២ | ៧ | ១ | | | |
| ៥ | ន.ប កណ្តាល | **៤** | **៥** | **០** | ២ | ៣ | 0 | ២ | ២ | 0 | | | |
| ៦ | ន.ប កំពង់ចាម | **២** | **២** | **១** | ២ | ២ | ១ | | | | | | |
| ៧ | ន.ប ព្រះសីហនុ | **១** | **១** | **០** | ១ | ១ | 0 | | | | | | |
| ៨ | ន.ប សៀមរាប | **១** | **១** | **១** | ១ | ១ | ១ | | | | | | |
| ៩ | ន.ប ស្ទឹងត្រែង | **១** | **១** | **០** | ១ | ១ | 0 | | | | | | |
| ១០ | ន.ប កំពត | **០** | **១** | **០** | | | | | | | 0 | ១ | 0 |
| ១១ | ន.ប បាត់ដំបង | **១** | **៣** | **១** | ១ | ២ | ១ | | | | 0 | ១ | 0 |
| ១២ | ន.ប បន្ទាយមានជ័យ | **២** | **២** | **១** | ២ | ២ | ១ | | | | | | |
| ១៣ | ន.ប ពោធិសាត់ | **១** | **១** | **០** | ១ | ១ | 0 | | | | | | |
| ១៤ | ន.ប ក្រចេះ | **១** | **២** | **១** | ១ | ២ | ១ | | | | | | |
| ១៥ | អ.ហ ព្រៃវែង(ពាមរក៏) | **១** | **១** | **០** | ១ | ១ | 0 | | | | | | |
| **សរុប** | | **៣៧** | **៦០** | **១៥** | **៣៣** | ៤៩ | ១៤ | **៤** | ៩ | ១ | **០** | ៣ | 0 |

## ទិន្នន័យសារធាតុគីមីផ្សំដែលមានអាជ្ញាប័ណ្ណនាំចូល ខែសីហា ឆ្នាំ២០១០

| *ឈ្មោះសារធាតុគីមី* | *ក្រសួងសុខាភិបាល* | | *ក្រសួងឧស្សាហកម្ម* | | *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* | | *សរុប* | |
|---|---|---|---|---|---|---|---|---|
| | Kg | L | Kg | L | Kg | L | Kg | L |
| Glacial Acetic Acid | | | | | 50.000 | | **50.000** | |
| NAOH | | | | | 55.000 | | **55.000** | |
| Soda Ash | | | | | 1.100.000 | | **1.100.000** | |
| Sodium Sulfate | | | | | 4.400.000 | | **4.400.000** | |
| Calcium Carbonate | | | | | 100.000 | | **100.000** | |
| Formic Acid | | | | | 50.000 | | **50.000** | |
| Acetone | | | | | 75.000 | | **75.000** | |
| Methylene Choride | | | | | 62.000 | | **62.000** | |
| Methyl Ethyl Ketone | | | | | 7.000 | | **7.000** | |
| Toluene | | | | | 26.440 | | **26.440** | |
| Sodium Bicarbonate | | | | | 8.000 | | **8.000** | |
| ***Total :*** | | | | | **5.933.440** | | **5.933.440** | |

## ខេត្ត/អង្គភាព/អង្គការ ដែលបានធ្វើការងារផ្សព្វផ្សាយអប់រំ ក្នុងខែសីហា ឆ្នាំ២០១០

| អង្គភាព | ខ្លឹមសារផ្សព្វផ្សាយ | គោលដៅផ្សព្វផ្សាយ និង សមាសភាពចូលរួម | ចំនួន |
|---|---|---|---|
| -លេខាធិការដ្ឋាន គ្រ.ញ កំពង់ធំ<br>-ស្នងការដ្ឋាន ន.ប ខេត្តកំពង់ធំ<br>-អភិបាលស្រុក | -គ្រោះថ្នាក់នៃគ្រឿងញៀន<br>-ធ្វើបច្ចុប្បភាពបញ្ជីសណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត | កងទ័ព គ្រួសារយោធិន នគរបាលប៉ុស្តិ៍រដ្ឋបាល មេក្រុម១០ខ្នង ប្រជាជនស្រុកប្រាសាទសំបូរ ស្រុកសន្ទុក ស្រុកបារាយ ស្រុកស្ទោង ស្រុកកំពង់ស្វាយ មេក្រុម ១០ខ្នង បុគ្គលិក កម្មករ ក្រុមហ៊ុន កុល វាំសនា( ដាំដើមអាកាស្យា) | ៣.១៩២ នាក់ |
| ន.ប កំពង់ឆ្នាំង | -ផ្សព្វផ្សាយច្បាប់<br>-គ្រោះថ្នាក់នៃគ្រឿងញៀន | មុខសញ្ញាចែកចាយប្រើប្រាស់ ន.ប ស្រុក ន.ប ប៉ុស្តិ៍ មេឃុំ ចៅសង្កាត់ | ១៣៥ នាក់ |
| ន.ប កំពង់ស្ពឺ | គ្រោះថ្នាក់នៃគ្រឿងញៀន | ចំណុចគោលដៅ មុខសញ្ញាគោលដៅងាយទទួលរងគ្រោះ នៅក្រុងច្បារមន | ៤៣ នាក់ |
| -សាលាខេត្តកែប<br>-ស្នងការដ្ឋាន អធិការដ្ឋាន ក្រុងកែប<br>-អាជ្ញាធរក្រុងកែប | គ្រោះថ្នាក់នៃគ្រឿងញៀន | ប្រជាពលរដ្ឋក្រុងកែប | ១៨២ នាក់ |
| -ស្នងការដ្ឋាន ន.ប ឧត្តរមានជ័យ<br>-អធិការដ្ឋាន ន.ប ស្រុក | គ្រោះថ្នាក់នៃគ្រឿងញៀន | ប្រជាពលរដ្ឋ ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល ស្រុកសំរោង | ៤៨៧ នាក់ |
| -ស្នងការដ្ឋាន ន.ប ព្រះវិហារ<br>-អាជ្ញាធរស្រុករវៀង | គ្រោះថ្នាក់នៃគ្រឿងញៀន | ប្រជាពលរដ្ឋនៅក្រុងព្រះវិហារ ស្រុករវៀង | ៧៦៩ នាក់ |
| -គណៈកម្មាធិការ.គ្រ.ញ ព្រៃវែង<br>-ស្នងការដ្ឋាន ន.ប ព្រៃវែង<br>-មន្ទីរទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា | -ច្បាប់គ្រឿងញៀន<br>-ប្រៀបសមរភូមិប្រឆាំង គ្រ.ញ<br>-គ្រោះថ្នាក់នៃគ្រឿងញៀន<br>-ទិវាអន្តរជាតិ ២៦/៦/២០១០ | ន.ប ស្រុកបាភ្នំ ស្រុកមេសាង ន.ប ប៉ុស្តិ៍រដ្ឋបាល ក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ ព្រះសង្ឃ មន្ទីរជុំវិញខេត្ត កម្លាំងប្រដាប់អាវុធ ប្រជាពលរដ្ឋ អាចារ្យ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ អាហារដ្ឋាន | ១.៥១៣ នាក់ |
| -គណៈកម្មាធិការ. គ្រ.ញ ខេត្តស្វាយរៀង | -ប្រៀបសមរភូមិប្រឆាំង គ្រ.ញ<br>-ច្បាប់ត្រួតពិនិត្យគ្រឿងញៀន | នគរបាល ក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ ប្រជាជន | ១២១ នាក់ |
| បណ្តាញសមាគមយុវជនខ្មែរ សមាគមនារី លេខាធិការដ្ឋានគ្រឿងញៀន មន្ទីរសង្គមកិច្ច មន្ទីរសុខាភិបាល មន្ទីរអប់រំយុវជននិងកីឡា ខេត្តប៉ៃលិន | គ្រោះថ្នាក់នៃគ្រឿងញៀន | ស្ត្រីបំរើសេវាកម្សាន្ត និង យុវវ័យតាមទីសាធារណៈ អ្នកបំរើតាមសណ្ឋាគារ | ២.៤៤១ នាក់ |
| **សរុប** | | | **៨.៨៨៣ នាក់** |